# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៥៧...សសរ

## សេចក្តីសំរេច

### ស្តីពី

### ការបន្ថែមសមាសភាពគណៈកម្មការចំរុះអន្តរក្រសួង ដោះស្រាយបញ្ហារថយន្តចង្កូតស្តាំ

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងសេចក្តីសំរេចលេខ០៣ សសរ ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០០១ របស់រាជរដ្ឋាភិបាលស្តីពីការបង្កើតគណៈកម្មការចំរុះអន្តរក្រសួង ដោះស្រាយបញ្ហារថយន្តចង្កូតស្តាំ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន និងជាប្រធានគណៈកម្មការចំរុះអន្តរក្រសួង ដោះស្រាយបញ្ហារថយន្តចង្កូតស្តាំ

## សំរេច

**ប្រការ១.**-លោក តៅ ម៉ាលី អគ្គនាយករងនៃអគ្គនាយកដ្ឋានដឹកជញ្ជូន ត្រូវបានតែងតាំងជាលេខាធិការរងអចិន្ត្រៃយ៍របស់គណៈកម្មការចំរុះអន្តរក្រសួងដោះស្រាយបញ្ហារថយន្តចង្កូតស្តាំ ។

www.pheakdeylaw.com

<u>**ប្រការ២.**</u>-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន និង សាមីខ្លួន ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី២០ ខែ កញ្ញា ឆ្នាំ២០០១

ឧបនាយករដ្ឋមន្ត្រី

<u>**ចំលងជូន**</u>

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
"<u>ដើម្បីជូនជ្រាប</u>"។
-ដូចប្រការ១ និងប្រការ២
"<u>ដើម្បីអនុវត្ត</u>"។
-ឯកសារ-កាលប្បវត្តិ ។

www.pheakdeylaw.com